# បេឡាជាតិរបបសន្តិសុខសង្គម
(ប.ស.ស)

## ខិត្តប័ណ្ណ សម្រាប់កម្មករនិយោជិត
## ផ្នែកថែទាំសុខភាព

### តាវកាលិកថែទាំសុខភាពរួមមាន៖

កញ្ចប់តាវកាលិក | សេវាបង្ការសុខភាព






### សម្រាប់ព័ត៌មានទាក់ទងនឹង ប.ស.ស

លេខទូរស័ព្ទព័ត៌មានបន្ទាន់: 1286 (24ម៉ោង/7ថ្ងៃ)
ទូរស័ព្ទលេខ: 023 882 623/ 023 88 24 34
Facebook ប.ស.ស : www.facebook.com/nssfpage
គេហទំព័រ: www.nssf.gov.kh

### អ្វីជារបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព?

សំដៅដល់ការផ្តល់ការព្យាបាល និងថែទាំវេជ្ជសាស្រ្ត សេវាបង្ការ និងប្រាក់បំណាច់ប្រចាំថ្ងៃដោយមានជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ និងសម្រាកមាតុភាព។

### លក្ខខណ្ឌដើម្បីទទួលបានតាវកាលិក

១.កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុង ប.ស.ស ផ្នែកថែទាំសុខភាព និងមានប័ណ្ណសមាជិក ប.ស.ស ទោះបីជានិយោជកមិនទាន់បង់ភាគទានសម្រាប់ខែដំបូងក៏ដោយ។

២.បានបង់យ៉ាងតិច ០៦(ប្រាំមួយ)ខែ ក្នុងអំឡុងពេល ១២ (ដប់ពីរ)ខែចុងក្រោយគិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព។

ក្នុងករណីដែលសមាជិក ត្រូវបានបង់ភាគទាន ០២(ពីរ)ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទានសមាជិកមានសិទ្ធិទទួលសេវាព្យាបាល និងថែទាំវេជ្ជសាស្រ្តរយៈពេល ២(ពីរ)ខែថែមទៀត គិតពីកាលបរិច្ឆេទនៃការអស់កាតព្វកិច្ចបង់ភាគទាន។

### សេវាមិនរាប់បញ្ចូល

១-ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងនៅក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
២-ការថែទាំធ្មេញ (ការសំអាត ការប៉ះធ្មេញ និងការដាក់ធ្មេញ)
៣-ការព្យាបាល និងការវះកាត់ប្តូរភេទ
៤-ការផ្សាំ ឬប្តូរសរីរាង្គផ្សេងៗ
៥-សេវាបង្កកំណើតដោយសិប្បនិម្មិត
៦-ការព្យាបាលដោយខ្លួនឯង
៧-ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ
៨-ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
៩-ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
១០-ការព្យាបាលអសមត្ថភាពផ្តល់កំណើត
១១-ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
១២-ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
១៣-ការលាងឈាម
១៤-ការពិនិត្យសុខភាពទូទៅ

*បញ្ជាក់៖ ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចបានចែងខាងលើត្រូវបានផ្តល់ជូន។*

### ការផ្តល់សេវាប្រភេទជំងឺរ៉ាំរ៉ៃ

ការផ្តល់សេវាពិគ្រោះជំងឺក្រៅ និងសម្រាកពេទ្យ ហើយប្រើប្រាស់តែឱសថសារវន្ត ដែលមាននៅក្នុង មូលដ្ឋានសុខាភិបាលសាធារណៈប៉ុណ្ណោះ។

ការផ្តល់សេវាចំពោះជម្ងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ នឹងត្រូវប្រើប្រាស់ឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះឱសថព្យាបាល ក្រៅបញ្ជីឱសថសារវន្តជាបន្ទុកចំណាយផ្ទាល់របស់អ្នកជម្ងឺ លើកលែងតែឱសថព្យាបាលជម្ងឺទឹកនោមផ្អែម និងជម្ងឺលើសសម្ពាធឈាម មិនមាននៅក្នុងឱសថសារវន្ត និងការព្យាបាលជម្ងឺមហារីកដោយសារធាតុគីមីត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ

ប្រភេទជំងឺរ៉ាំរ៉ៃទាំងនេះមានជាអាទិ៍៖
១-ជំងឺខ្សោយបេះដូង
២-ជំងឺសាច់ដុំបេះដូង
៣-ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ
៤-ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ
៥-ជំងឺតំរងនោមរ៉ាំរ៉ៃ
៦-ជំងឺក្រិនថ្លើម
៧-ជំងឺសរសៃឈាមក្រហមបេះដូង
៨-ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២
៩-ជំងឺវិបត្តិចង្វាក់បេះដូង
១០-ជំងឺក្រិនសរីរាង្គ
១១-ជំងឺវិកលចរិត
១២-ជំងឺលុយពុស
១៣-ជំងឺលើសឈាម
១៤-ជំងឺតាឡាសសីមី

### សេវាបង្ការសុខភាពរួមមាន៖

១-សេវាចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត
២-សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត
៣-សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស
៤-សេវាចាក់សេរ៉ូម ប្រឆាំង ពិសពស់
៥-សេវាពិនិត្យឈាមរកជំងឺពក ក មាន៖ TSH (Thyroid Stimulating Hormone) និងFree T3(Free Triiodothyronine) Free T4 (Free Thyroxine)
៦-សេវាពិនិត្យឈាមកំណត់អបោធាតុមហារីក ក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមី និង/ឬ ក្រោយការព្យាបាលជំងឺមហារីក ដោយបាញ់កាំរស្មីអ៊ិច មាន៖ CA15-3 (Cancer Antigen 15-3), CA19-9 (Cancer Antigen 19-9), Ca125 (Cancer Antigen 125), PSA (Prostate-Specific Antigen), HCG (Beta-Human Chorionic Gonadotropin)

# តាវកាលិក (អត្ថប្រយោជន៍) ថែទាំសុខភាពដែលកម្មករនិយោជិតទទួលបានមាន ការផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការសុខភាពរួមមាន៖

## ក.កញ្ចប់តាវកាលិកសុខភាព

### ក.១.សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

**-ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ៖**

សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត សម្ភារបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល ឱសថតាមវេជ្ជបញ្ជា បន្ទប់(ធម្មតា) និងអាហារដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។



**-សេវាពិគ្រោះជំងឺក្រៅ៖**សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ រូបភាពវេជ្ជសាស្ត្រ សេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត បរិក្ខារសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ ការព្យាបាល និងឱសថតាមវេជ្ជបញ្ជា។



**-សេវាសង្គ្រោះបន្ទាន់** ជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺឬជនរងគ្រោះ។

**-សេវាព្យាបាលដោយស្ពំ និងដោយចលនា**







**-សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុន និងក្រោយពេលសម្រាលកូន ។**





**-សេវាស្តារនីតិសម្បទា** ផ្តល់ដោយ ប.ស.ស កម្មវិធីជាតិអង្គភាព ឬ ស្ថាប័ន និងអង្គការទាក់ទងទៅនឹងការស្តារនីតិសម្បទាដទៃទៀត។





### ក.២-សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព





### ក.៣-ប្រាក់បំណាច់ប្រចាំថ្ងៃ៖

១- ដើម្បីទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- ត្រូវបានបង់ភាគទាន ផ្នែកថែទាំសុខភាពក្នុងរយៈពេល ០២ខែជាប់គ្នា ឬបានបង់យ៉ាងតិច ០៦(ប្រាំមួយ)ខែ ក្នុងអំឡុង១២(ដប់ពីរ) ខែចុងក្រោយគិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព និងកំពុងបំពេញការងារ
- ត្រូវបានបង់ភាគទានបាន ០៩ខែ ក្នុងអំឡុងពេល ១២(ដប់ពីរ) ខែចុងក្រោយគិតរហូតមកទល់ខែដែលបានសម្រាលកូន។

២- ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០%(ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំថ្ងៃរបស់សាមីជន សម្រាប់រយៈពេលអាក់ខានការងារដោយសារការសម្រាកព្យាបាលថែទាំជម្ងឺឬរបួស តាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី ០៧(ប្រាំពីរ)ថ្ងៃ ដោយរាប់ចាប់ពីថ្ងៃទី១ ដែលកម្មករនិយោជិតបានចូលទៅមូលដ្ឋានសុខាភិបាល។ ការផ្តល់ប្រាក់បំណាច់នេះផ្តល់ជូនមិនលើស១៨០(មួយរយប៉ែតសិប)ថ្ងៃ ក្នុងរយៈពេល ១២(ដប់ពីរ)ខែចុងក្រោយដោយមិនរាប់បញ្ចូលរយៈពេលសម្រាកមាតុភាព៩០(កៅសិប)ថ្ងៃ ។

***ប្រាក់បំណាច់ប្រចាំថ្ងៃនេះ ប.ស.ស ផ្តល់ជូនចំនួន ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ របស់កម្មករនិយោជិត។***

## ខ.សេវាបង្ការសុខភាព

សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឱ្យមានបញ្ហាសុខភាពមានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ។ សេវាបង្ការសុខភាពផ្តល់ដោយ ប.ស.ស កម្មវិធីជាតិអង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត។

## ***ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រដោយឥតគិតថ្លៃ កម្មករនិយោជិត

ត្រូវភ្ជាប់មកជាមួយនូវបណ្ណសមាជិកភាព ប.ស.ស ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអេឡិចត្រូនិច ឬឯកសារផ្សេងទៀតដែលអាចកំណត់អត្តសញ្ញាណសមាជិក ប.ស.ស បានហើយទៅប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះព្រមព្រៀងជាមួយ ប.ស.ស មានសំគាល់ដោយរូបសញ្ញា (LOGO) ប.ស.ស ចំនួន ១ ៣១៩កន្លែង (គិតត្រឹមខែមិថុនា ឆ្នាំ២០១៨) ។